# សេចក្តីថ្លែងការណ៍

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦

## រយៈពេលមួយខែកន្លងមកហើយ យុទ្ធនាការ#ដោះលែងអ្នកទាំង៥ នៅតែបន្តស្នើឱ្យមានការដោះលែងអ្នកការពារសិទ្ធិមនុស្ស

នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ នេះ ជាថ្ងៃគម្រប់មួយខែចាប់តាំងពីបើកយុទ្ធនាការ #ដោះលែងអ្នកទាំង៥ និងអស់រយៈពេល ១៣៣ ថ្ងៃហើយដែលអ្នកការពារសិទ្ធិមនុស្សទាំង៥នាក់ត្រូវបន្តជាប់ឃុំនៅពន្ធនាគារក្រោមការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដែលការចោទប្រកាន់ទាំងនេះត្រូវបានគេយល់ឃើញថាធ្វើឡើងក្រោមហេតុផលនយោបាយ។

ចាប់តាំងពីថ្ងៃចាប់ផ្តើមមក យុទ្ធនាការ #ដោះលែងអ្នកទាំង៥ បានទទួលការគាំទ្រយ៉ាងខ្លាំងទាំងនៅក្នុងប្រទេសកម្ពុជា ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។ កាតប៉ូស្តាល់ជិត៣០០សន្លឹកដែលបានសរសេរសារផ្តល់កម្លាំងចិត្ត និងការគាំទ្រ ត្រូវបានប្រមូល ដែលនៅក្នុងនោះកាតចំនួន ១៤០ ត្រូវបានយកទៅជូនអ្នកជាប់ឃុំទាំង៥ នៅពន្ធនាគារព្រៃស និងពន្ធនាគារនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។ បន្ថែមពីលើចំនួនអង្គការសង្គមស៊ីវិលនៅកម្ពុជា និងអង្គការអន្តរជាតិចំនួន៥២ស្ថាប័ន ដែលបានចេញសេចក្តីថ្លែងការណ៍គាំទ្រយុទ្ធនាការតាំងពីដំបូងមក ក៏មានក្រុមសង្គមស៊ីវិលពីរផ្សេងទៀតបានចូលរួមគាំទ្រយុទ្ធនាការនេះផងដែរ។

បើទោះជាការគាំទ្រយុទ្ធនាការនេះទទួលបានការលើកទឹកចិត្តយ៉ាងណាក្តី ក៏រហូតមកទល់ពេលនេះសកម្មជនទាំង៥នាក់នៅតែបន្តស្ថិតក្នុងពន្ធនាគារនៅឡើយ ហើយមិនដឹងថាពេលណាទើបពួកគាត់នឹងត្រូវដោះលែងនោះទេ។ នៅថ្ងៃទី០៥ ខែកញ្ញា តុលាការកំពូលបានពន្យារពេលសវនាការលើសំណើសុំនៅក្រៅឃុំរបស់លោក នី សុខា លោក យី សុខសាន្ត លោក ណៃ វង់ដា និងអ្នកស្រី លឹម មុនី ដែលកំពុងជាប់ឃុំបណ្តោះអាសន្នដោយមិនអនុលោមតាមច្បាប់កម្ពុជា និងមិនស្របនឹងសិទ្ធិទទួលបានសេរីភាព និងការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគាត់ដែលធានាជាអន្តរជាតិ។ ក្រៅពីត្រូវចោទប្រកាន់បីបទសមគំនិតក្នុងការសូកប៉ាន់ លោក នី ចរិយា ក៏ត្រូវប្រឈមនឹងការជំនុំជម្រះក្តីនៅថ្ងៃទី២២ ខែកញ្ញា ពីបទបរិហារកេរ្តិ៍ ដែលជាបទចោទដាច់ដោយឡែកមួយផ្សេងទៀតដែលប្តឹងដោយមន្ត្រីតុលាការខេត្តសៀមរាប។

ជាមួយគ្នានេះដែរ យើងឃើញថាកាលពីខែមុន ករណីយាយីទៅលើសង្គមស៊ីវិល និងការរឹតត្បិតទៅលើសេរីភាពជាមូលដ្ឋានកាន់តែមានសភាពធ្ងន់ធ្ងរខ្លាំងឡើងនៅក្នុងប្រទេសកម្ពុជា។ មកដល់ត្រឹមចុងខែសីហា មានការចាប់ខ្លួនចំនួន ៣៦ ករណី លើមនុស្សយ៉ាងតិចចំនួន ២០ នាក់ នៅពេលតវ៉ាក្នុងយុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅ ព្រមទាំងការចាប់ខ្លួនអ្នកតវ៉ាចំនួន៦នាក់ទៀតនៅថ្ងៃច័ន្ទ ទី០៦ ខែកញ្ញា ហើយពួកគាត់ត្រូវបានឃុំខ្លួនពេញមួយយប់។ អ្នកដែលត្រូវចាប់ខ្លួនទាំង៦នេះ រួមមាន ពីរនាក់ជាប្រជាសហគមន៍បឹងកក់ ដែលមានម្នាក់ជាដៃគូរៀបចំយុទ្ធនាការ #ដោះលែងអ្នកទាំង៥។ អ្នកស្រី ទេព វន្នី និងអ្នកស្រី បូវ សោភា ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៥ ខែសីហា ហើយបន្ទាប់ពីការជំនុំជម្រះក្តីរយៈពេល ៩០នាទីនៅថ្ងៃទី២២ ខែសីហា ចៅក្រមបានប្តូរបទ

ចោទនៅនាទីចុងក្រោយដោយចោទពីបទ «ប្រមាថមន្ត្រីសាធារណៈ»។ អ្នកស្រី បូវ សោភា ត្រូវបានដោះលែងវិញដោយសារអ្នកស្រីបានអនុវត្តទោសរយៈពេល ៦ ថ្ងៃរួចហើយក្នុងពេលឃុំខ្លួន ដោយឡែកអ្នកស្រី ទេព វន្នី ត្រូវបន្តឃុំខ្លួនបណ្ដោះអាសន្នពាក់ព័ន្ធនឹងបទចោទមួយផ្សេងទៀតនៅពេលមានការតវ៉ាមួយក្នុងឆ្នាំ២០១៣ ដែលសំណុំរឿងនេះត្រូវបានពន្យារនីតិវិធីកន្លងមក។

យុទ្ធនាការ #ដោះលែងអ្នកទាំង៥ នឹងនៅតែបន្ត ដរាបណាអ្នកទាំង៥នាក់នៅតែត្រូវគេឃុំខ្លួន និងអំពាវនាវឱ្យសាធារណជនផ្ញើសារលើកទឹកចិត្តដល់អ្នកទាំង៥ ដើម្បីរំលឹកដល់ពួកគាត់ថា សាធារណជនមិនបំភ្លេចគាត់ឡើយ និងនៅតែជួយផ្ដល់កម្លាំងចិត្តដល់ពួកគាត់ឱ្យមានស្មារតីរឹងមាំ ខណៈកំពុងស្ថិតនៅក្នុងពន្ធនាគារ។

សម្រាប់ព័ត៌មានបន្ថែមពីការចូលរួមយុទ្ធនាការនេះ សូមចូលទៅកាន់គេហទំព័រ www.freethe5kh.net ហ្វេសប៊ុក និងធ្វីតទ័រ ឬ ទាក់ទងយើងខ្ញុំតាមរយៈអ៊ីម៉ែល freethe5kh@gmail.com៕